# របៀបប្រើសេចក្ដីបកប្រែនៃសន្លឹកនេះ៖

- អានព័ត៌មាននៅពីលើគំរូខាងក្រោមនេះ
- បំពេញផ្នែកដែលស្របគ្នានៅពីលើប័ណ្ណភាសាអង់គ្លេស សម្រាប់អ្នកដំណើរចូលមកក្នុងប្រទេស

# សូមកុំសរសេរនៅលើសន្លឹកនេះឲ្យសោះ (ជាគំរូប៉ុណ្ណោះ)

SAMPLE

**ប័ណ្ណអ្នកដំណើរចូលមកក្នុងប្រទេស • អូស្ត្រាលី**

សូមបំពេញជាភាសាអង់គ្លេស ដោយប្រើប៊ិចពណ៌ខៀវ ឬពណ៌ខ្មៅ

- ▶ នាមត្រកូល
- ▶ នាមខ្លួន
- ▶ លេខលិខិតឆ្លងដែន
- ◆ លេខយន្តហោះ ឬឈ្មោះកប៉ាល់
- ▶ អាសយដ្ឋានដែលបានគ្រោងទុកក្នុងប្រទេសអូស្ត្រាលី

រដ្ឋ

- ▶ តើលោកអ្នកមានបំណងនឹងរស់នៅក្នុងប្រទេសអូស្ត្រាលីសម្រាប់រយៈពេល១២ខែខាងមុខនេះឬ? បាទ / ចាស់ ☐ ទេ ☐
- ▶ ប្រសិនបើលោកអ្នក**មិនមែនជាពលរដ្ឋអូស្ត្រាលី:**
  - តើលោកអ្នកមានរោគរបេងឬទេ? បាទ / ចាស់ ☐ ទេ ☐
  - តើលោកអ្នកមានការផ្ដន្ទាទោសខាងបទឧក្រិដ្ឋណាមួយឬទេ? បាទ / ចាស់ ☐ ទេ ☐

សូម ☒ ហើយឆ្លើយគ្រប់ទាំងសំណួរ – ប្រសិនបើមិនច្បាស់ប្រាកដទេ បាទ / ចាស់ ☒

▶ តើលោកអ្នកនាំចូលមកក្នុងប្រទេសអូស្ត្រាលី:

| | | | |
|---|---|---|---|
| 1. | ទំនិញដែលបានហាមឃាត់ ឬនៅក្រោមការកំហិត ដូចជាថ្នាំពេទ្យ ស្តេរ៉យ្ដ (steroids) រូមអាសគ្រាមដែលខុសច្បាប់ កាំភ្លើង អាវុធ ឬគ្រឿងញៀនខុសច្បាប់? | បាទ / ចាស់ ☐ | ទេ ☐ |
| 2. | ភេសជ្ជៈមានជាតិសុរាច្រើនជាង២២៥០មីលីលីត្រ ឬបារីច្រើនជាង២៥ ឬផលិតផលថ្នាំជក់ចំនួន២៥ក្រាម? | បាទ / ចាស់ ☐ | ទេ ☐ |
| 3. | ទំនិញដែលទទួលបានពីបរទេស ឬទិញដែលបានបង់ពន្ធ និង/ឬរួចពន្ធក្នុងប្រទេសអូស្ត្រាលី ដែលមានតម្លៃរួមសរុបច្រើនជាង $900 អូស្ត្រាលី មានរួមទាំងអំណោយផងដែរ? | បាទ / ចាស់ ☐ | ទេ ☐ |
| 4. | ទំនិញ/គំរូសាកសម្រាប់អាជីវកម្ម/ពាណិជ្ជកម្មប្រើប្រាស់? | បាទ / ចាស់ ☐ | ទេ ☐ |
| 5. | ប្រាក់ចំនួន $10,000 អូស្ត្រាលី ឬច្រើនជាងនេះ ឬរូបិយវត្ថុបរទេសស្មើនឹងចំនួននេះ? **កំណត់ចំណាំ:** ប្រសិនបើភ្នាក់ងារគយ ឬប៉ូលិសសួរ លោកអ្នកត្រូវរាយការណ៍អំពី travellers cheques (មូលប្បទានប័ត្រអ្នកធ្វើដំណើរ) មូលប្បទានប័ត្រ money orders ឬអ្នកកាន់ឯកសារធានាលើការបង់ប្រាក់ដែលអាចចរាចាគ្នាបាននៃចំនួនណាមួយ។ | បាទ / ចាស់ ☐ | ទេ ☐ |
| 6. | សាច់ សាច់មាន់ទា ត្រី សាច់សត្វសមុទ្រ ស៊ុត ផលិតផលធ្វើពីជាតិទឹកដោះគោ ផ្លែឈើ បន្លែ? | បាទ / ចាស់ ☐ | ទេ ☐ |
| 7. | ធញ្ញជាតិ គ្រាប់ពូជ មើម ចំបើង គ្រាប់(ផ្លែឈើ) រុក្ខជាតិ ផ្នែកនៃរុក្ខជាតិ ថ្នាំបូរាណ ឬថ្នាំតិណទេស វត្ថុធ្វើពីឈើ? | បាទ / ចាស់ ☐ | ទេ ☐ |
| 8. | សត្វ ផ្នែកនៃសត្វ ផលិតផលធ្វើអំពីសត្វ មានរួមទាំងគ្រឿងបរិក្ខា ចំណីសត្វ ស៊ុតខាងជីវសាស្ត្រ សំណាក បក្សី ត្រី សត្វល្អិត សំបកខ្យងខ្មៅ ផលិតផលធ្វើពីឃ្មុំ? | បាទ / ចាស់ ☐ | ទេ ☐ |
| 9. | ដី វត្ថុទាំងឡាយដែលមានជាប់ដី ឬប្រើនៅក្នុងទីកន្លែងទឹកសាប ឧទាហរណ៍ គ្រឿងបរិក្ខាកីឡា/កំសាន្ត ស្បែកជើង? | បាទ / ចាស់ ☐ | ទេ ☐ |
| ▶ 10. | តើលោកអ្នកមានដែលទាក់ទងប៉ះជាមួយនឹងទីកន្លែងនៅតាមកសិដ្ឋាន កសិដ្ឋានសត្វ ទីរហោឋាន ឬខ្សែទឹកសាប បឹង។ល។ ក្នុងរយៈពេល៣០ថ្ងៃកន្លងមកនេះឬទេ? | បាទ / ចាស់ ☐ | ទេ ☐ |
| ▶ 11. | តើលោកអ្នកបាននៅប្រទេសអាហ្វ្រិក អាមេរិកខាងត្បូង/កណ្ដាល ឬ Caribbean (ខារីប៊ីន) ក្នុងរយៈពេល៦ថ្ងៃកន្លងមកនេះឬទេ? | បាទ / ចាស់ ☐ | ទេ ☐ |

**សេចក្ដីប្រកាស**

*ព័ត៌មានដែលខ្ញុំបានផ្ដល់គឺពិត ត្រឹមត្រូវ ហើយពេញលេញ។ ខ្ញុំយល់ថា ការធ្វេសប្រហែសពុំបានឆ្លើយទៅនឹងសំណួរណាមួយ អាចមានផលពិបាកយ៉ាងធ្ងន់ធ្ងរ។*

ហត្ថលេខារបស់លោកអ្នក

ថ្ងៃ ខែ ឆ្នាំ

សូមបើកទៅប័ណ្ណម្ខាងទៀត ▶

**ព័ត៌មានទាក់ទងលំអិតនៅក្នុងប្រទេសអូស្ត្រាលី**

ទូរស័ព្ទ ( )

អ៊ីម៉ែល

ឬ

អាសយដ្ឋាន រដ្ឋ

**ព័ត៌មានទាក់ទងលំអិតក្នុងគ្រាអាសន្ន (គ្រួសារ ឬមិត្តភក្តិ)**

ឈ្មោះ

អ៊ីម៉ែល

ទូរស័ព្ទ ឬ

អាសយដ្ឋានផ្ញើតាមប៉ុស្តិ៍

**សូមបំពេញជាភាសាអង់គ្លេស**

▶ តើលោកអ្នកជិះយន្តហោះ ឬកប៉ាល់នេះពីប្រទេសណា?

◆ តើលោកអ្នកមានមុខអាជីពធម្មតាជាអ្វី?

▶ សញ្ជាតិដូចបង្ហាញនៅពីលើលិខិតឆ្លងដែន

▶ ថ្ងៃខែឆ្នាំកំណើត ថ្ងៃ ខែ ឆ្នាំ

▶ សូម ✕ ហើយឆ្លើយ **A** ឬ **B** ឬ **C**

**A** ការផ្លាស់ទីលំនៅជាអចិន្ត្រៃយ៍មកកាន់ប្រទេសអូស្ត្រាលី

**B** អ្នកចូលមកជាភ្ញៀវ ឬជាបណ្ដោះអាសន្ន

▶ រយៈពេលដែលលោកអ្នកមានបំណងនឹងស្នាក់នៅក្នុងប្រទេសអូស្ត្រាលី ឆ្នាំ ខែ ឬ ថ្ងៃ

▶ ប្រទេសដែលលោកអ្នករស់នៅ

**C** ពលរដ្ឋវិលត្រឡប់មកកាន់ប្រទេសអូស្ត្រាលីវិញ

▶ ប្រទេសដែលលោកអ្នកចំណាយពេលច្រើនជាងគេនៅឯបរទេស

**សូមឲ្យបានប្រាកដថាលោកអ្នកបានបំពេញប័ណ្ណនេះទាំងសងខាង។ សូមបង្ហាញប័ណ្ណនេះជាមួយនឹងលិខិតធ្វើដំណើររបស់លោកអ្នកនៅពេលអញ្ជើញមកដល់។**

▶ មូលហេតុដ៏សំខាន់របស់លោកអ្នកចំពោះការធ្វើដំណើរ (✕ តែមួយប៉ុណ្ណោះ)

| | | | |
|---|---|---|---|
| សន្និបាត / សន្និសីទ **1** | ទៅលេងមិត្តភក្តិ ឬញាតិសន្តាន **3** | ការអប់រំ **5** | សំរាកកំសាន្ត **7** |
| ពាណិជ្ជកម្ម **2** | ការងារ **4** | ការតាំងពិព័រណ៍ **6** | ផ្សេងទៀត **8** |

ព័ត៌មានដែលស្នើសុំនៅលើប័ណ្ណនេះ តម្រូវដើម្បីយកទៅចាត់ចែងច្បាប់អន្តោប្រវេសន៍ គយ ការដាក់ឲ្យនៅដាច់ពីគេ ស្ថិតិ សុខភាព សត្វព្រៃ និងរូបិយវត្ថុឯទៀតនៃប្រទេសអូស្ត្រាលី ហើយការប្រមូលនេះត្រូវបានអនុញ្ញាតដោយច្បាប់។ ព័ត៌មាននេះនឹងបានបញ្ចេញឲ្យដឹងប៉ុណ្ណោះ ទៅភ្នាក់ងារទាំងឡាយដែលចាត់ចែងផ្នែកទាំងនេះ ហើយត្រូវបានអនុញ្ញាត ឬតម្រូវឲ្យទទួលយកព័ត៌មាននេះនៅក្រោមច្បាប់អូស្ត្រាលី។ ហ្វ៉មលេខ 1442i *Privacy notice* *(ដំណឹងអំពីរឿងឯកជន)* អាចទទួលយកបាននៅតាម **https://immi.homeaffairs.gov.au/help-support/departmental-forms**

07191503

© Commonwealth of Australia 2019



SAMPLE